ហេតុពិត ?



ហេតុពិត ?

នៅមាន ខ្មែរយើងជាច្រើន ភ្ញាក់ផ្អើល នូវ អំពើលោក ហ៊ុន សែន រំលាយ គណបក្សសង្គ្រោះជាតិ ព្រោះប្រហែលយល់ឃើញថា ស្រុកខ្មែរ ជាប្រទេស ផ្តត់ផ្តង់ ដោយ លទ្ធិប្រជាធិបតេយ្យ ដូច្នេះ ទង្វើ របស់លោក ហ៊ុន សែន វា បំពាន នូវ គោលការណ៍ នៃ លទ្ធិ នេះ។ តែតាមពិត នៅស្រុកខ្មែរ ទោះបី មាន កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ជាបង្គង់ នៃ របបដឹកនាំ ដែលជាឆន្ទៈ របស់ អង្គការសហប្រជាជាតិ តែ ក្រុមភាគីខ្មែរ នៅពេលនោះ សុទ្ធតែដឹកនាំដោយ ជន ភ្ជានស្ការតី នៃ លទ្ធិប្រជាធិបតេយ្យ បន្ទិចបន្ទួចនោះឡើយ។

សម្តេច សីហនុ

សព សម្តេចសីហនុ ទ្រង់ មានធម្មជាតិ ជា ស្តេចផ្តាច់ការ មានស្ការតី អញ្ញនិយម ជាស្តែដុះស្ទឹម ពុំអាចឲទ្រង់យល់ដឹងអំពី គុណប្រយោជន៍ នៃ លទ្ធិប្រជាធិបតេយ្យ សំរាប់ ប្រជាជាតិខ្មែរ នោះទេ។ អ្វីដែលព្រះអង្គចង់បានគឺ អំណាចស្តេច និង ការវិលត្រឡប់ នៃ របបរាជានិយម តែប៉ុណ្ណោះ ដូច្នេះ ព្រះអង្គ ភ្ជាន ជារម្ភអ្វី នឹងធ្វើ សម្ព័ន្ធមេត្រី ជាមួយភាគីណា ដែលអាចឲរាជ បំណង អាចនឹងសំរេចបាន។

ហេតុពិត ?

សម្តេច ស៊ីន សាន

សព សម្តេច ស៊ីន សាន លោក ជា អ្នកអភិរក្សនិយម មានការ ចេះដឹងខ្ពង់ខ្ពស់ តែលោកយល់ឃើញ ថា ការចេះដឹង របស់ លោក ជា វត្ថុល្អប្រសើរ និង មានប្រយោជន៍ ទុកវាជា តម្លៃ ទី១ សំរាប់លោក និង សង្គមខ្មែរ។ ល្បាយ នូវ ធម្មជាតិ នៃ អភិរក្ស និយម និង គំនិត ជឿនលឿននិយម នៅក្នុង ស្មារតី របស់ លោក វាទាញលោក ទៅរក ស្មារតី នៃ ការណនិយម (pragmatisme) ក្នុង ជីវិតរស់នៅ ក៏ដូច ជីវិតភាពនយោបាយ របស់លោក, គឺពោលថា លោក ប្រព្រឹត្តអ្វីមួយ ទៅតាម ប្រយោ ជន៍ផ្ទាល់ខ្លួន របស់លោក។ ដូច្នេះ លោក ពុំអាចដើរតួ ជា ប្រមុខ នៃ ចលនា នៃ លទ្ធិប្រជាធិបតេយ្យ មូលវ៉ាន់ដ[1] បាននោះ ឡើយ។

ភាគីខ្មែរក្រហម

ភាគីខ្មែរក្រហម ជា ភាគីកុម្មុយនិស្ត, ចារី នៃ អំពើឃាតកម្ម ប្រឆាំងនឹងមនុស្សជាតិ, ដឹកនាំដោយ ក្រុមបញ្ញាវន្តមួយក្តាប់ ខ្វះបស្សុស: (manque d'inspiration) នៃ ការរួបរួមជាតិ និង ការពិត នៃ វិស័យមតិ នៃ ប្រជាពលរដ្ឋខ្មែរ មកលើខ្លួន, នាំគ្នា នឹកស្រមៃយថា ពួកខ្លួន អាចបន្តអនុវត្ត នូវ គំនិតហួសវិស័ យឃាត (utopie meurtrière) ក្នុងសង្គមជាតិ ដែលពួកខ្លួន កំ

[1] ចលនា នៃលទ្ធិប្រជាធិបតេយ្យ មូលវ៉ាន់ដ; mouvement de la démocratie radicale។

ហេតុពិត ?

ទិចឲក្លាយជាដេះ ហើយ ធ្លាក់ទៅក្នុង កណ្តាប់ដៃយួនកុម្មុយនិស្ត។ ពួកនោះ នឹកស្មានថា ការអំពាវនាវ ឲពលរដ្ឋខ្មែរ រៃយួនវាគ្រប់គ្រាន់ សំរាប់បង្ហាញ នូវ គំនិតស្នេហាជាតិ របស់ខ្លួន ដូច្នេះ មិននាំគ្នា ប្រឹងប្រែងកែ មនោគមវិជ្ជា មិនស្របនឹងសង្គម អោយត្រូវតាម លទ្ធិប្រជាធិបតេយ្យពិតប្រាកដ ដែលវាជា ចម្លើយទោល នៃ សេចក្តីត្រូវការ នៃ បរិបទសង្គម និងនយោបាយ របស់ ប្រជាជាតិខ្មែរ នៅចំពោះមុខ ពលក្តារ (menace) នៃ មហិច្ឆិតា របស់យួនកុម្មុយនិស្ត។

ភាគីបក្សប្រជាជន

ភាគីបក្សប្រជាជន ជាភាគី រណបយួនកុម្មុយនិស្ត មានគោលដៅច្បាស់លាស់ គឺ រក្សាអំណាចផ្តាច់ការ ដែលជា មធ្យោបាយតែមួយគត់ សំរាប់ អត្តភាព របស់ខ្លួន។ គ្មានអំណាចផ្តាច់ការ គឺ មរណភាព តែប៉ុណ្ណោះ ដូច្នេះ ត្រូវធ្វើអ្វីគ្រប់បែបយ៉ាង មានទាំងអំពើ ហឹង្សា, ឃាតកម្ម ដើម្បី រក្សាអំណាចនោះ។ ភាគីនេះ ដឹកនាំដោយ គណបក្សកុម្មុយនិស្តយួនផ្ទាល់ យក ខ្មែរមួយចំនួន ជា ទូកញ្ចក់តាំងអំណាចខ្មែរ សំរាប់ បំភាន់ សហគមអន្តរជាតិ ថា ប្រទេសខ្មែរ ជាប្រទេសឯករាជ្យ មានអធិបតេយ្យភាព ពិតប្រាកដ។ ពួកខ្មែរបំរើយួន ភាគច្រើន ជាអតិតខ្មែរក្រហម ដែលយួនគេយកមកលៀងសំអាត ល្ហមប្រើការបាន សំរាប់ បំពេញបេសកកម្មដែលគេ បង្ហាប់ឲធ្វើតាមឥតខ្ចោះតែប៉ុណ្ណោះ។

ហេតុពិត ?

យើងឃើញថា ការរួបរួមជាតិ នៅក្នុង ស្មារតី កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា វា គ្មាន សម្ថានភាព ពីសំណាក់ភាគីខ្មែរនោះឡើយ ព្រោះធាតុ នៃ ភាគីទាំងនោះ វា ផ្ទុយទាំងស្រុង ពីស្មារតី នៃ កិច្ចព្រមព្រៀងសន្តិភាព។ គោលការណ៍ នៃ កិច្ចព្រមព្រៀង គឺចង់បាន សន្តិភាព នៅក្នុង ក្របខណ្ឌ នៃ លទ្ធិប្រជាធិបតេយ្យសេរី, រីឯ ភាគីខ្មែរនិមួយៗ វិញ គឺចង់រក្សា បុព្វសិទ្ធិ របស់ខ្លួន និង ស្វែងរកមធ្យាបាយគ្រប់បែបយ៉ាង ដើម្បី ធ្វើ១សំ រេច នូវ គោលបំណងរបស់ខ្លួន រៀងៗខ្លួន។ ដូច្នេះ វាគ្មាន សាមគ្គីភាព, ជនុបត្ថម្ភ (entraide) ក្នុងអត្ថប្រយោជន៍ជាតិ នោះឡើយ។ ការលាយ ពណ៌ខ្មៅ ជាមួយ ពណ៌ខ្មៅ វាមិនអាចដូរ ១ទៅជា ពណ៌ផ្សេងទៀតបានឡើយ ពោលថា បើភាគីទាំងនោះ គាត់មានស្មារតីផ្តាច់ការដូចគ្នា វាបញ្ចេញ នូវ លទ្ធផលមួយ គឺ ថា អ្នកផ្តាច់ការ ណាម្នាក់ ខ្លាំងជាងគេ នឹងដណ្តើមអំណាច បាននោះឯង។ ដូច្នេះ ជ័យជំនះ របស់លោក ហ៊ុន សែន នៅ ពេលនេះ វាជា កម្ម១ិបាក អាចស្ថានបាន តាំងពីដំបូងមក ម្លេះ។ តែគេអាចសួរបានថា តើវាជា ជ័យជំនះ ជាស្ថាពរ ដែរ ឬទេ ?